អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា
Kampuchea Action to Promote Education (KAPE)

# លិខិតជូនដំណឹង

- ពី : លោក សៅ វណ្ណា នាយកប្រតិបត្តិ អង្គការ ខេប
- ជូនចំពោះ : លោក/លោកស្រី ជាប្រធានក្រុមហ៊ុន និងអ្នកម៉ៅការសំណង់
- ចម្លងជូន : លោក សរ សុផាណាក់ ប្រធានគម្រោង IDEAL
  លោក ឈួន សារ៉ាន ប្រធានរដ្ឋបាល និងធនធានមនុស្ស
  លោក បូ សម្បត្តិ នាយកហរិញ្ញវត្ថុ
- កម្មវត្ថុ : ការដំកល់ប្រាក់កក់ធានារ៉ាប់រងសម្រាប់ចូលរួមដេញថ្លៃទទួលការងារជួសជុលបន្ទប់សិក្សា បណ្ណាល័យ/បន្ទប់កុំព្យូទ័រ និងបំពាក់គ្រឿងសង្ហារឹម នៅតាមសាលារៀនគោលដៅគម្រោង IDEAL។
- កាលបរិច្ឆេទ : ថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤។

---

ដោយយោងទៅតាមគោលនយោបាយលទ្ធកម្មបានចែង និងអនុលោមតាមអនុសាសន៍របស់គណៈកម្មការក្រុមអ្នកគ្រប់គ្រងជាន់ខ្ពស់របស់អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា បានសម្រេចជាឯកច្ឆន្ទឱ្យក្រុមហ៊ុន និងអ្នក **ម៉ៅការសំណង់ ទាំងអស់ដែលមានសិទ្ធិចូលរួមដេញថ្លៃ តម្រូវឱ្យមានការដំកល់ប្រាក់កក់ធានារ៉ាប់រងដើម្បីចូលរួមដេញថ្លៃចំនួន ៥% នៃចំនួនទឹកប្រាក់ដេញថ្លៃសរុប (ក្នុងមួយផ្នែក) បញ្ចប់ត្រឹមថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ៤:០០ល្ងាចជាកំហិត ដើម្បីមានសិទ្ធិចូលរួមបើកកញ្ចប់ដេញថ្លៃ។** ប្រសិនបើក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ណាដែលមិនបានជាប់ក្នុងការដេញថ្លៃនោះទេ អង្គការនឹងបង្វែរប្រាក់កក់ទាំងអស់គ្រប់ចំនួនទៅឱ្យក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ វិញក្នុងរយៈពេលមួយសប្តាហ៍ក្រោយដេញថ្លៃរួច។

<u>សូមបញ្ជាក់ថា៖</u> ប្រសិនបើក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ ណាដែលមិនបានបង់ដំកល់ប្រាក់កក់ធានារ៉ាប់រងសម្រាប់ចូលរួមដេញថ្លៃ ៥% (ក្នុងមួយផ្នែក) ខាងលើ អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងមិនអនុញ្ញាតឱ្យមានសិទ្ធិចូលរួមដេញថ្លៃ និងចូលរួមបើកកញ្ចប់ដេញថ្លៃនោះទេ ហើយកញ្ចប់ឯកសារដេញថ្លៃត្រូវចាត់ទុកជាអាសារបង់ និងនិរាករណ៍។

☺ អសយដ្ឋាន និងលេខគណនីធនាគារដែលត្រូវការបង់ប្រាក់កក់ធានារ៉ាប់រងមានលម្អិតដូចខាងក្រោម៖

**១. ធនាគារ អេស៊ីលីដា (ACLEDA) សាខាខេត្ត កំពង់ចាម**

- ឈ្មោះគណនី៖ KAPE SAVINGS
- លេខគណនី៖ 1000-20-151963-18

• *Head Offices: Provincial Teacher Training College of Kampong Cham Kampong Cham Town, Kampong Cham Province.*
• *Mailing Address: PO Box1621, Post Office, P. Penh. Tel.: 042-941-481, 042- 941-918; E-mail: kape@kapekh.org; www.kapekh.org*

២. ធនាគារ អេប៊ីអេ (ABA) សាខាខេត្ត កំពង់ចាម

- ឈ្មោះគណនី៖ Kampuchea Action To Promote Education Organization
- លេខគណនី៖ 002 373 992

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ យើងខ្ញុំសង្ឃឹមទុកជាមុនថា លោក/លោកស្រី ជាម្ចាស់ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ ទាំងអស់មានការយោគយល់អធ្យាស្រ័យចំពោះសេចក្ដីជូនដំណឹងនេះ ហើយសង្ឃឹមថានឹងមានឱកាសជួបគ្នាក្នុងពេលឆាប់ៗខាងមុខតាមកាលបរិច្ឆេទកំណត់ ដើម្បីធ្វើការបើកកញ្ចប់ដេញថ្លៃទទួលការងារជួសជុលបន្ទប់សិក្សាសម្រាប់បណ្ណាល័យ/បន្ទប់កុំព្យូទ័រ និងបំពាក់គ្រឿងសង្ហារឹម តាមសាលារៀនគោលដៅរបស់គម្រោង "លើកកម្ពស់ការអប់រំឌីជីថលសម្រាប់សិស្សានុសិស្ស"។

**សូមគោរព និងសូមអរគុណ**!

**អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា**

**នាយកប្រតិបត្តិ**

សៅ_ចំណ្ណា